របាយការណ៍ឃ្លាំមើលសភា និងតំណាងរាស្ត្ររបស់ខុមហ្វ្រែលពីខែតុលា ដល់ខែធ្នូ ២០១០នេះ គឺស្រប ពេលជាមួយសម័យប្រជុំរបស់រដ្ឋសភាលើកទី ៥ នីតិកាលទី ៤។

ក្នុងរបាយការណ៍លេខនេះ ខុមហ្វ្រែលនឹងបង្ហាញការសង្កេតនានាទាក់ទងនឹងសម័យប្រជុំពេញអង្គការ ពិភាក្សា និងអនុម័តរបៀបវារៈ និងសេចក្តីព្រាង/ស្នើច្បាប់នានានៅក្នុងសម័យប្រជុំរដ្ឋសភា។

ទោះបីរដ្ឋសភាប្រជុំក្តី ការប្រជុំនេះមានតែ ៦ពេល (ព្រឹក/ថ្ងៃ) ប៉ុណ្ណោះ ហើយក្រៅពីនេះ អ្នកតំណាងរាស្ត្រក៏បានយកពេលវេលាចុះមូលដ្ឋានជួបម្ចាស់ឆ្នោត និងភាគីពាក់ព័ន្ធនានាផងដែរដូចជាអាជ្ញាធរមូលដ្ឋាន និងសមាជិកគណបក្សរបស់ខ្លួនជាដើម។

## ការសង្កេតសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី ៥

### អ្នកតំណាងរាស្ត្រទទួលបានអត្ថបទច្បាប់ និងរបៀបវារៈសម្រាប់ពិភាក្សាក្នុងរយៈពេលដ៏ខ្លី

ជាថ្មីម្តងទៀត ក្នុងសម័យប្រជុំលើកទី៥នេះ អ្នកតំណាងរាស្ត្រមួយចំនួនបន្តបង្ហាញពីការមិនពេញចិត្តចំពោះនីតិវិធីរបស់រដ្ឋសភាដែលផ្តល់អត្ថបទច្បាប់ដែលត្រូវពិភាក្សា និងអនុម័តកៀកពេលនឹងសម័យប្រជុំពេញអង្គរដ្ឋសភា ដែលជាមធ្យមប្រហែល ៣ថ្ងៃ។

នៅក្នុងសម័យប្រជុំលើកទី៥នេះ មានអត្ថបទសេចក្តីព្រាងច្បាប់ និងស្នើច្បាប់ចំនួន ៧ ដែលត្រូវពិភាក្សា និងអនុម័ត ក៏ប៉ុន្តែភាគច្រើននៃអត្ថបទសេចក្តីព្រាង/ស្នើច្បាប់នេះបានទៅដល់ដៃតំណាងរាស្ត្រគ្រប់រូបតែ ២ ឬ៣ថ្ងៃ មុនថ្ងៃប្រជុំ និងពិភាក្សាអនុម័តតែប៉ុណ្ណោះ។

ដូចជាអត្ថបទសេចក្តីព្រាងច្បាប់ស្តីពីការកែតម្រូវហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១០ ត្រូវបានដាក់ឲ្យតំណាងរាស្ត្រថ្ងៃសុក្រ ឬ ១ថ្ងៃនៃថ្ងៃធ្វើការ មុនសម័យប្រជុំពេញអង្គដែលធ្វើឡើងថ្ងៃច័ន្ទ។

ក៏ប៉ុន្តែ បញ្ហានេះមិនបានជាឧបសគ្គសម្រាប់តំណាងរាស្ត្រគណបក្សកាន់អំណាចនោះទេ ដោយសារតំណាងរាស្ត្រគណបក្សនេះបានគ្រប់គ្រងគ្រប់គណៈកម្មការជំនាញទាំងអស់របស់រដ្ឋសភា ដូចនេះអ្នកតំណាងរាស្ត្រគណបក្សនេះ អាចចែករំលែក និងផ្តល់ព័ត៌មានឲ្យគ្នា និងមានពេលគ្រប់គ្រាន់សិក្សាពីច្បាប់ទាំងនេះតាំងពីចូលសភាលើកទីមួយម្ល៉េះ។ រាល់សេចក្តីព្រាងច្បាប់ទាំងអស់ មុននឹងក្លាយជារបៀបវារៈសម្រាប់សម័យប្រជុំពេញអង្គ គឺត្រូវឆ្លងកាត់ការសិក្សា និងពិភាក្សានៅក្នុងគណៈកម្មការណាមួយ ឬច្រើនរបស់រដ្ឋសភាតាមជំនាញ និងការចាត់តាំងរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

ដោយឡែកតំណាងរាស្ត្រគណបក្សជំទាស់ទាំងគណបក្ស សមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស សុទ្ធតែមិនមានវត្តមាននៅក្នុងគណៈកម្មការណាមួយនោះទេ ជាហេតុនាំឲ្យអ្នកតំណាងរាស្ត្រទាំងនេះមិនបានទទួលអត្ថបទមុនទេ។

អ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** និង **សុន ឆ័យ** មកពីគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញបានបង្ហាញពីការអាក់អន់ចិត្តនៅពេលសភាកោះប្រជុំបន្តលើកទី ៥នៅថ្ងៃទី ២៧ ធ្នូ ២០១០ ដោយខ្លួនបានទទួលរបៀបវារៈចាស់ ហើយរបៀបវារៈថ្មីមិនត្រូវបានជូនដំណឹងមុនឲ្យបានទាន់ពេល។

អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានថ្លែងថា *"យើងមានរបៀបវារៈថ្មី មានការងារត្រូវពិនិត្យ និងអនុម័តលើច្បាប់ និងកិច្ចព្រមព្រៀងចំនួន៤ ខុសពីអ្វីដែលជាសេចក្តីអញ្ជើញដែលរដ្ឋសភាទទួលបាន ដែលមានរបៀបវារៈចំនួន១។ យើងខ្ញុំឃើញភ្លាមឥតបានយកឯកសារមក ធ្វើឲ្យមានការលំបាកបន្តិចដែរ។ យ៉ាងហោចណាស់យើងបានដឹងមុនបន្តិចថា ត្រូវថែមរបៀបវារៈអ្វីខ្លះទៅ? ដើម្បីយើងអាចចូលរួមការពិភាក្សាលើច្បាប់ និង/ឬកិច្ចព្រមព្រៀងបានល្អប្រសើរ។ [ វា ] ជាការភ្ញាក់ផ្អើលមួយដែរព្រឹកនេះ "*។

ចំណែកអ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** បានបង្ហាញចម្ងល់ថា *"ឯកឧត្តម [រដ្ឋសភា] មានពេលគ្រប់គ្រាន់សំរាប់អញ្ជើញរាជរដ្ឋាភិបាលមកជជែកការពារច្បាប់ ប៉ុន្តែគ្មានពេលប្រាប់អ្នកតំណាងរាស្ត្រថា របៀបវារៈទី៩ [ប្តូរ] មកសេចក្តីព្រៀងច្បាប់នេះវិញ"*។

អ្នកតំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជន និងជាប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភាបានបញ្ជាក់ជូនរដ្ឋសភាថា ការកែប្រែ ក៏ដូចជាការបន្ថែមរបៀបវារៈនេះ គឺដោយសារលើកទី១ គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចម្តងរួចហើយ តែរបៀបវារៈថ្មីនោះ គឺចូលក្រោយ ហើយក៏មានការប្រជុំបន្ថែមរបៀបវារៈលើទី ២ទៀត៖ *"សូមជម្រាបថា សេចក្តីព្រាងច្បាប់នេះ [ច្បាប់កែតម្រូវហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១០] មកដល់រដ្ឋសភាថ្ងៃ១៣ ខែធ្នូ ឆ្នាំ២០១០ ក្រោយពេល [ការប្រជុំសំរេចលើកមុនរបស់] គណៈកម្មាធិការអចិន្ត្រៃយ៍"*។

ចំណែកអ្នកតំណាងរាស្ត្រ **គាត ឈន់** និងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលតំណាងឲ្យរាជរដ្ឋាភិបាលមកការពារសេចក្តីព្រាងច្បាប់នេះបានបញ្ជាក់ក្នុងនាមជាតំណាងរាស្ត្រថា *"[ខ្ញុំ]បានឃើញរបៀបវារៈទាំង៤។ តែខាងឯកឧត្តមគណបក្សប្រឆាំងឃើញតែមួយ។ ខ្ញុំឋានៈជាតំណាងរាស្ត្របាន៤ដែរ។"*

បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋសភានៅថ្ងៃទី ២១ ធ្នូ បានបញ្ជាក់ថា នៅថ្ងៃប្រជុំទី ២៧ខែធ្នូ មានរបៀបវារៈតែ ១ ប៉ុណ្ណោះ។

ទោះបីយ៉ាងណា របៀបវារៈត្រូវបានបន្ថែម៣ទៀត ហើយចែកជូន និងផ្សព្វផ្សាយដល់តំណាងរាស្ត្រនៅថ្ងៃ ២៤ សម្រាប់ការប្រជុំថ្ងៃ ២៧ (ថ្ងៃ ២៥ និង២៦ គឺជាថ្ងៃសៅរ៍ និងអាទិត្យ)។

ដូចនេះ អ្នកតំណាងរាស្ត្រមួយចំនួនបានទទួលសេចក្តីព្រាង និងរបៀបវារៈនៅថ្ងៃប្រជុំតែម្តង។

គណៈកម្មាធិការខុមប្រែ្វលយល់ឃើញថា សេចក្តីព្រាងច្បាប់ដែលចូលដល់រដ្ឋសភា គួរតែធ្វើការផ្សព្វផ្សាយជាសាធារណៈ និងចែកជូនដល់គ្រប់តំណាងរាស្ត្រ ដើម្បីធ្វើការសិក្សា និងផ្តល់ជាមតិ ឬអនុសាសន៍ដល់គណៈកម្មការជំនាញដែលត្រូវពិភាក្សាជាមួយតំណាងរាជរដ្ឋាភិបាលដែលមកការពារច្បាប់។ ហើយកាលបរិច្ឆេទប្រជុំក្នុងគណៈកម្មការជំនាញ និងកាលបរិច្ឆេទប្រជុំរវាងរដ្ឋាភិបាល ជាមួយគណៈកម្មការជំនាញ ក៏ត្រូវប្រកាសជាសាធារណៈតាមរយៈវ៉េបសាយសភា និងប្រព័ន្ធផ្សព្វផ្សាយរដ្ឋជាដើម ដើម្បីឲ្យភាគីពាក់ព័ន្ធបានដឹងអំពីរបៀបវារៈ និងត្រៀមការចូលរួមមតិ។

ខុមប្រែ្វលក៏កោតសរសើរយន្តការទំនាក់ទំនងរវាងអគ្គលេខាធិការដ្ឋានរដ្ឋសភា និងអ្នកតំណាងរាស្ត្រតាមរយៈការសរសេរលិខិតអញ្ជើញតំណាងរាស្ត្រមកប្រជុំនៅរដ្ឋសភា និងការទូរស័ព្ទជូនដំណឹង។ ទោះបីយ៉ាងណា លិខិតអញ្ជើញនោះ គឺដាក់ក្នុងប្រអប់សំបុត្រតំណាងរាស្ត្រនៅក្នុងរដ្ឋបាលសភា ហើយការទូរស័ព្ទជូនដំណឹងក៏មិនបានគ្រប់គ្នាដែរ។ ដើម្បីសម្រួលដល់ការជូនដំណឹងនេះ ខុមប្រែ្វលសូមផ្តល់យោបល់ "**បង្កើតប្រព័ន្ធសារទូរស័ព្ទ (SMS) ឬប្រព័ន្ធ E-mail**"។ ក្នុងន័យនេះ នៅពេលអគ្គលេខាធិការដ្ឋានរដ្ឋសភាមានរបៀបវារៈឬសេចក្តីព្រាងច្បាប់/ស្នើច្បាប់ ឬការកែប្រែរបៀបវារៈដែលត្រូវប្រគល់ ឬជម្រាបជូនគ្រប់តំណាងរាស្ត្រ អគ្គលេខាធិការដ្ឋានរដ្ឋសភា គួរផ្ញើសារដល់តំណាងរាស្ត្រទាំងអស់ជាដំណឹង បន្ថែមទៅលើការសរសេរលិខិតអញ្ជើញ និងការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិចទាំងនេះ។

ក្នុងសម័យប្រជុំលើកទី៥ នេះ ដែលមានរយៈពេលពីខែតុលា ដល់ ខែធ្នូ ឆ្នាំ ២០១០ រដ្ឋសភាបានបើកសម័យប្រជុំរបស់ខ្លួនចំនួន ៦ ពេល (ព្រឹក/ថ្ងៃ) ដោយបានពិភាក្សា ឬ/និង អនុម័តរបៀបវារៈសរុបចំនួន ១៣។ ក្នុងនោះរួមមានសេចក្តីព្រាងច្បាប់/ស្នើច្បាប់ចំនួន ៧ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ១ ការបំភ្លឺផ្ទាល់មាត់នៅរដ្ឋសភាដោយតំណាងរាជរដ្ឋាភិបាល ១ និងផ្សេងៗចំនួន ៤។

*<u>សេចក្តីព្រាងច្បាប់/ស្នើច្បាប់ដែលរដ្ឋសភាបានពិភាក្សា និងអនុម័តក្នុងសម័យប្រជុំលើកទី៥នេះមានៈ</u>*

- សេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន អូស្ត្រាលី ណូវែលហ្សេឡង់
- សេចក្តីព្រាងច្បាប់ ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- សេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ
- សេចក្តីព្រាងច្បាប់កែតម្រូវ ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០

- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុភាគី អាស៊ានស្តីពីសេរីភាវូបនីយកម្មពេញលេញនៃសេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសរួមទាំងពិធីសារចំនួន២និងកិច្ចព្រមព្រៀងពហុភាគីអាស៊ានស្តីពីសេវាកម្មដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសរួមទាំងពិធីសារចំនួន៦
- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើៈ
    - កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋឥណ្ឌា
    - កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ច សហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា
    - កិច្ចព្រមព្រៀងស្តីពីយន្តការដោះស្រាយជម្លោះក្រោមកិច្ចព្រមព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា
- សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា

## តំណាងរាស្ត្រជំទាស់ពហិការស្តាប់ការបំភ្លឺផ្ទាល់មាត់របស់រាជរដ្ឋាភិបាលក្នុងសភា

តំណាងរាស្ត្រជំទាស់មកពីគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានដើរចេញពីសាលប្រជុំរដ្ឋសភា នៅពេលដែលខ្លួនមិនត្រូវបានឲ្យបញ្ចេញមតិ ឬសួរទៅរាជរដ្ឋាភិបាលដែលឡើងមកបំភ្លឺរដ្ឋសភាជុំវិញប្រាក់បៀវត្សរបស់កម្មករ។

នៅក្នុងឱកាសដ៏កម្រដែលខាងរាជរដ្ឋាភិបាលមកបំភ្លឺផ្ទាល់មាត់នៅរដ្ឋសភា តាមការស្នើសុំរបស់អ្នកតំណាងរាស្ត្រនោះ បែរជាត្រូវប្រធានអង្គប្រជុំដែលជាអនុប្រធានទី១រដ្ឋសភាបានហាមមិនឲ្យអ្នកតំណាងរាស្ត្រសួររាជរដ្ឋាភិបាលទៅវិញ ដោយគ្រាន់តែអនុញ្ញាតឲ្យរាជរដ្ឋាភិបាលនិយាយឆ្លើយនឹងសំណួរដែលតំណាងរាស្ត្របានសួរនៅពេលដាក់លិខិតតែប៉ុណ្ណោះ។

នៅថ្ងៃទី ២១ ខែតុលា រាជរដ្ឋាភិបាលបានចាត់តាំង ឯកឧត្តម **វង សូត្រ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមកឆ្លើយបំភ្លឺសំណួររបស់អ្នកតំណាងរាស្ត្រ **សុន ឆ័យ** មកពីគណបក្សសមរង្ស៊ី នៅវិមានរដ្ឋសភាលើភាពមិនប្រក្រតីមួយចំនួនដែលកើតមានពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ក្រសួង ការតវ៉ារបស់កម្មករពាក់ព័ន្ធនឹងការតំលើងប្រាក់ខែអប្បបរិមា និងការគ្រប់គ្រង និងការពារដល់កម្មករដែលធ្វើការនៅបរទេស។

នៅខណៈដែលតំណាងរាស្ត្រ **សុន ឆ័យ** ចង់អាននូវសំណួររបស់ខ្លួនដើម្បីឱ្យតំណាងរាជរដ្ឋាភិបាល ក៏ដូចជាតំណាងរាស្ត្របានស្តាប់ ក៏ត្រូវបានហាមឃាត់ដោយប្រធានអង្គប្រជុំ អ្នកតំណាងរាស្ត្រ **ងួន ញ៉ិល** ដែលជាអនុប្រធានទី ១រដ្ឋសភា មកពីគណបក្សប្រជាជនកម្ពុជា។

អ្នកតំណាងរាស្ត្រ **សុន ឆ័យ** ដែលជាម្ចាស់សំណួរបានបង្ហាញការមិនពេញចិត្ត ហើយបានទទូចយ៉ាងហោចណាស់បានអានសំណួរដែលខ្លួនដាក់ដល់រាជរដ្ឋាភិបាល ជូនសមាជិករដ្ឋសភាឲ្យបានដឹង។

ទោះបីយ៉ាងណា ប្រធានអង្គប្រជុំបានបដិសេធមិនឲ្យអាន ដោយចាត់ទុកថា វាជាសំណួរបន្ថែម ហើយអាចមិនមានពេលគ្រប់គ្រាន់សម្រាប់តំណាងរាជរដ្ឋាភិបាលឆ្លើយ។

ជាលទ្ធផលដោយមិនអាចធ្វើអ្វីទៀតបាន អ្នកតំណាងរាស្ត្រ **សុន ឆ័យ** និងអ្នកតំណាងរាស្ត្រដទៃទៀតមកពីគណបក្សសមរង្ស៊ី និងសិទ្ធមនុស្ស បានដើរចេញពីសាលប្រជុំ។ ចំណែករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈ ឯកឧត្តម **វង សូត្រ** ក៏បានអានបំភ្លឺទៅនឹងសំនួរដែលមានក្នុងលិខិតដែលសួរដោយអ្នកតំណាងរាស្ត្រ **សុន ឆ័យ** ដោយគ្មានការសួរដេញដោល និងគ្មានវត្តមានម្ចាស់សំណួរ។

មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញផ្តល់សិទ្ធដល់តំណាងរាស្ត្រក្នុងការដាក់សំណួរដល់រាជរដ្ឋាភិបាលឲ្យបំភ្លឺតាមរយៈ លិខិត ឬផ្ទាល់មាត់។ ក្នុងករណីបំភ្លឺផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចឲ្យមាន ឬមិនមានការជជែកដេញដោល។ ក្នុងនីតិកាលទី ៤ ឃើញមានការបំភ្លឺផ្ទាល់មាត់នៅសភាចំនួន ៣ ដងមកហើយ ដែលការមកបំភ្លឺខ្លះមានការបើកឲ្យមានការពិភាក្សាដេញដោល ខ្លះមិនមាន។ ខុមប្រែ្វលយល់ឃើញការប្រជុំរបស់សភា (រួមទាំងការសួរដេញដោលទៅរាជរដ្ឋាភិបាល) ត្រូវបានការអនុញ្ញាតឲ្យពិភាក្សាដាក់សំណួរផ្ទាល់មាត់ ព្រោះជាការការពារ និងការគោរពសិទ្ធិបញ្ចេញមតិផ្ទាល់មាត់របស់អ្នកតំណាងរាស្ត្រក្នុងពេលប្រជុំ។

## សំលេងអ្នកតំណាងរាស្ត្រ ភាគតិចមិនត្រូវបានឮក្នុងពេលប្រជុំពេញអង្គរដ្ឋសភាលើកទី ៥

នៅក្នុងសម័យប្រជុំពេញអង្គលើកទី៥នេះដែលមានរយៈពេលពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រដែលមកពីគណបក្សមានអាសនៈតិចជាង១០ រួមមានគណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សហ៊្វុនស៊ិនប៉ិច មិនបានបញ្ចេញមតិទាល់តែសោះនៅក្នុងអំឡុងពេលប្រជុំ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ដែលកំណត់ឲ្យតំណាងរាស្ត្របង្កើតក្រុមដែលមានសមាជិកយ៉ាងតិច ១០រូប ទើបអាចបញ្ចេញមតិនៅសម័យប្រជុំពេញអង្គបានធ្វើឲ្យតំណាងរាស្ត្រដែលមកពីគណបក្សឈ្នះឆ្នោត តែមានអាសនៈតិចជាង១០ បាត់សំលេងទាំងស្រុងនៅសម័យប្រជុំពេញអង្គ ឬត្រូវបង្ខំចិត្តចូលរួមជាមួយក្រុមរបស់គណបក្សដទៃទៀត។

ទោះបីការពិភាក្សា និងអនុម័តច្បាប់ ហើយជាពិសេសសិទ្ធិសេរីភាពបញ្ចេញមតិគឺជាតួនាទីសំខាន់មួយរបស់អ្នកតំណាងរាស្ត្រដែលចែងក្នុងរដ្ឋធម្មនុញ្ញក៏ដោយ តែតំណាងរាស្ត្រភាគតិចត្រូវជួបឧបសគ្គអនុវត្តសិទ្ធិទាំងនេះដោយសារតែបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

សម័យប្រជុំទី៥នេះដែលមានរយៈពេល ៦ ពេល (ព្រឹក/ថ្ងៃ) ដែលមានការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ និងស្នើច្បាប់ចំនួន ៧ រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ គឺមិនមានការចូលរួមយោបល់ពិភាក្សាទាល់តែសោះពីតំណាងរាស្ត្រសម្លេងភាគតិចដែលសរុបតំណាងឲ្យម្ចាស់ឆ្នោតជាង ១ លាននាក់នោះ។

ផ្ទុយទៅវិញ ការបញ្ចេញមតិនៅប្រជុំពេញអង្គរដ្ឋសភាត្រូវបានគ្របដណ្តប់ដោយតំណាងរាស្ត្រសម្លេងភាគច្រើន គឺគណបក្សកាន់អំណាចប្រជាជនកម្ពុជា និងគណបក្សជំទាស់សមរង្ស៊ីប៉ុណ្ណោះ។

ប្រធានរដ្ឋសភាធ្លាប់បានលើកឡើងថា តំណាងរាស្ត្រដែលបញ្ចេញមតិនៅសម័យប្រជុំពេញអង្គត្រូវតែចូលជាសមាជិករបស់ក្រុមណាមួយ។ ក៏ប៉ុន្តែអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សដែលជាគណបក្សមានសម្លេងតិចក្នុងរដ្ឋសភាលើកឡើងថា ការចូលរួមជាសមាជិកក្រុមគណបក្សផ្សេង គឺមិនខុសពីបំបាត់សំលេងគណបក្សខ្លួននោះទេ ខណៈដែលគណបក្សនយោបាយមាននិន្នាការ និងគោលនយោបាយខុសៗគ្នា។

ជាមួយគ្នានេះ ការសង្កេតក៏បង្ហាញដែរថា បើទោះបីជាតំណាងរាស្ត្រភាគតិចចូលជាមួយក្រុមដទៃ ក៏ឱកាសបញ្ចេញមតិមានតិចតួចដែរ។

ដើម្បីធានានូវការបញ្ចេញមតិរបស់តំណាងរាស្ត្រមកពីគ្រប់គណបក្ស ជាពិសេសសម្លេងតំណាងរាស្ត្រភាគតិច បទបញ្ជាផ្ទៃក្នុងរដ្ឋសភាប្រការ ៤៨ថ្មី (ពីរ) ដែលចែងថា "អាសនានុក្រមនៃក្រុមតំណាងរាស្ត្រត្រូវរៀបជាក្រុមៗ តាមគណបក្សនយោបាយពីមុខទៅក្រោយ។ ក្រុមនីមួយៗត្រូវមានសមាជិកយ៉ាងតិចដប់រូប....។" គួរត្រូវធ្វើវិសោធនកម្ម ដោយ "អនុញ្ញាតឲ្យគណបក្សណាមួយមានសម្លេងតិចជាង ១០ អាចបង្កើតបានមួយក្រុម។"

បទបញ្ជាផ្ទៃក្នុងរដ្ឋសភាប្រការ ៤៨ ក៏ធ្លាប់ត្រូវបានវិសោធនកម្មកន្លងមកពីរដងរួចមកហើយក្នុងនីតិកាលទី៣ កន្លងមក គឺក្នុងឆ្នាំ ២០០៥ និង២០០៦ ដើម្បីធានាភាពរលូននៃការពិភាក្សា និងការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រនៅសម័យប្រជុំ។ ជាពិសេសការវិសោធនកម្មប្រការនេះនៅឆ្នាំ ២០០៦ ដោយបន្ថយចំនួនក្នុងក្រុមឡើងបញ្ចេញមតិពី ១៣ រូប មកនៅត្រឹម ១០រូប។

គួរបញ្ជាក់ថា ក្នុងនីតិកាលទី ៣ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានចំនួន ៧៣ រូប តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចចំនួន ២៦ រូប និងគណបក្សសមរង្ស៊ីចំនួន ២៤ រូប។ ការកំណត់សមាជិកក្រុមតំណាងរាស្ត្រ ១៣ រូប ក្នុងមួយក្រុមធ្វើឲ្យគណបក្សសមរង្ស៊ីអាចបង្កើតបានតែមួយក្រុមប៉ុណ្ណោះ តែការវិសោធនកម្មមកនៅត្រឹម ១០រូប បានធ្វើឲ្យគណបក្សនេះបាន ២ក្រុម។

ដូចនេះ ការវិសោធនកម្មនេះដោយអនុញ្ញាតឲ្យគណបក្សមានអាសនៈតិចជាង ១០ អាចបង្កើតក្រុមរបស់ខ្លួនបាន១ គឺជាការគោរពនូវស្មារតីរដ្ឋធម្មនុញ្ញនៃសិទ្ធិបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ និងការគោរពដល់សម្លេងភាគតិចផងដែរ។

## ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

តាមទិន្នន័យខុមហ្វ្រែលបង្ហាញថា ក្នុងរយៈពេល៣ខែនេះ (តុលា ដល់ ធ្នូ ២០១០) អ្នកតំណាងរាស្ត្របានចុះមូលដ្ឋានច្រើនជាងត្រីមាសមុន (កក្កដា-កញ្ញា ២០១០) បើទោះបីអ្នកតំណាងរាស្ត្រមានប្រជុំខ្លះៗនៅភ្នំពេញក៏ដោយ។

ក្នុងរយៈពេល៣ខែនេះដែលជាសម័យប្រជុំពេញអង្គលើកទី៥ផងដែរនោះ មានអ្នកតំណាងរាស្ត្រយ៉ាងតិច **៧៥**រូប (ឬ៦១% នៃអ្នកតំណាងរាស្ត្រសរុប ១២៣រូប) បានចុះមូលដ្ឋានសរុបបានយ៉ាងតិច **៤១៦** លើក។ ចំនួននេះបើប្រៀបធៀបទៅនឹងរយៈពេល៣ខែមុន គឺពីខែកក្កដា ដល់ខែកញ្ញា ដែលជារយៈពេលវិស្សមកាលគឺ មានការកើនឡើងប្រមាណ ៣០លើក។ តែចំនួនតំណាងរាស្ត្រដែលចុះមូលដ្ឋានវិញ គឺតិចជាង៣ខែមុនដែលមានរហូតដល់ ៨១រូប។

ក្នុងចំណោមតំណាងរាស្ត្រទាំង៧៥រូប ដែលបានចុះមូលដ្ឋាន មានតំណាងរាស្ត្រគណបក្ស**ប្រជាជនកម្ពុជា**សរុប**៥៥រូប** (ស្មើនឹង៦១% នៃតំណាងរាស្ត្រគណបក្សនេះសរុប៩០រូប)។ តំណាងរាស្ត្រគណបក្ស**សមរង្ស៊ី**សរុប **១៤រូប** (ស្មើនឹង៥៤%នៃតំណាងរាស្ត្រគណបក្សនេះសរុប ២៦រូប)។ ចំណែកតំណាងរាស្ត្រគណបក្ស**សិទ្ធិមនុស្ស**ចំនួន**៣រូប** និងតំណាងរាស្ត្រគណបក្ស**ហ៊្វុនស៊ិនប៉ិចទាំង ២ រូប**បានចុះមូលដ្ឋានទាំងអស់។ តំណាងរាស្ត្រគណបក្ស**នរោត្តមរណឫទ្ធិ ១រូប** ក្នុងចំណោម ២រូប បានចុះមូលដ្ឋាន។

បើគិតជាចំនួនចុះមូលដ្ឋានសរុបតាមគណបក្ស តំណាងរាស្ត្រគណបក្ស**ប្រជាជនកម្ពុជានិងអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី**បានចុះមូលដ្ឋានច្រើនជាងគេ ដោយសារគណបក្សទាំងពីរនេះមានអ្នកតំណាងរាស្ត្រច្រើន

ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជា**២៨៤លើក** និងគណបក្សសមរង្ស៊ីបាន **៩៨លើក**។ តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិចបាន**១៨ លើក** គណបក្សសិទ្ធិមនុស្ស **១៣លើក** និងគណបក្សនរោត្តមរណឫទ្ធិបាន **៣លើក**។

ទោះបីយ៉ាងណាបើគិតជាមធ្យមនៃតំណាងរាស្ត្រម្នាក់ៗដែលចុះមូលដ្ឋានតាមគណបក្សវិញ ឃើញថាតំណាងរាស្ត្រគណបក្ស**ហ៊្វុនស៊ិនប៉ិច**ជាមធ្យមចុះបានច្រើនជាងគេរហូតដល់**៩លើកក្នុង១រូប** តំណាងរាស្ត្រ**សមរង្ស៊ី**ជាមធ្យមម្នាក់បាន**៧លើក** តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាមធ្យមបាន **៥លើក** និងគណបក្ស**សិទ្ធិមនុស្ស** **៤លើក** និងគណបក្ស**នរោត្តមរណឫទ្ធិ ៣លើក**។

*ក្រាហ្វិកទី១៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស*




បើគិតតាម សមាមាត្រភាគរយនៃតំណាងរាស្ត្រក្នុងរដ្ឋសភាតាមគណបក្ស និងភាគរយនៃការចុះមូលដ្ឋានសរុបតាមគណបក្សបង្ហាញថា ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគឺ ស្ទើរតែសមាមាត្រទៅនឹងអាសនៈសភាដែលគណបក្សនីមួយៗទទួលបាន។

គណបក្ស**ប្រជាជនកម្ពុជា**ដែលមានអាសនៈសរុប **៧៣%** នៅរដ្ឋសភាតែចុះមូលដ្ឋានបាន **៦៨%** នៃការចុះមូលដ្ឋានសរុប ខណៈអ្នកតំណាងរាស្ត្រ គណបក្ស**សមរង្ស៊ី** មានអាសនៈ**២១%**នៅសភាបានចុះមូលដ្ឋាន **២៤%**។ តំណាងរាស្ត្រគណបក្ស៣ ទៀត គឺគណបក្ស**សិទ្ធិមនុស្ស** គណបក្ស**នរោត្តមរណឫទ្ធិ** និងគណបក្ស**ហ៊្វុនស៊ិនប៉ិច** ដែលរួមគ្នាមានអាសនៈ **៦%នៅសភា** ក៏បានខិតខំចុះទៅមូលដ្ឋានច្រើនដែរ ដែលស្មើនឹង៨%នៃការចុះមូលដ្ឋានសរុប។

*តារាងទី ១៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស*

| **គោលបំណងនៃការចុះមូលដ្ឋានទាំង ៤១៤លើក របស់ តំណាងរាស្ត្រទាំង៧៥រូប** | **គណបក្សនយោបាយ** | | | | | **សរុបគោលបំណង** |
|---|---|---|---|---|---|---|
| | ៥៥ រូប | ១៤ រូប | ៣ រូប | ២ រូប | ១ រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ១៩២ (៦៨%) | ៤៥ (៤៦%) | ៥ (៣៨%) | ៦ (៣៣%) | ០ | ២៤៨ (៦០%) |
| ការចុះពង្រឹងផ្ទៃក្នុង និង បណ្ដាញគណបក្ស | ៣២ (១១%) | ៤២ (៤៣%) | ៥ (៣៨%) | ៨ (៤៤%) | ១ (៣៣%) | ៨៨ (២១%) |
| ការចុះអមដំណើរជាក្រុម ឬ អមដំណើរថ្នាក់ដឹកនាំ | ៥៨ (២០%) | ០ | ១ (៨%) | ៣ (១៧%) | ០ | ៦២ (១៥%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ២ (១%) | ៥ (៥%) | ២ (១៥%) | ១ (៦%) | ២ (៦៧%) | ១២ (៣%) |
| ការអន្តរាគមន៍ និង ដោះស្រាយបញ្ហានានា | ០ | ៦ (៦%) | ០ | ០ | ០ | ៦ (១%) |
| **សរុបគោលបំណងតាមគណបក្ស** | ២៨៤ | ៩៨ | ១៣ | ១៨ | ៣ | ៤១៦ (១០០%) |

តារាងទី ១ បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រគឺ ផ្តោតទៅលើគោលបំណង **សាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់ ២៤៧លើក** (ឬ ៦០%នៃការចុះមូលដ្ឋានសរុប)។ ការចុះ**ពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន២១%**។ ការចុះអមដំណើរថ្នាក់ដឹកនាំ ១៥% និងការចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានតែ៣%។ ចំណែកការអន្តរាគមន៍ និងដោះស្រាយបញ្ហានានាគឺតិចជាងគេតែ ៦លើក ឬស្មើនឹង១% ប៉ុណ្ណោះ។

**-តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា:** អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាផ្តោតទៅលើការសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា មានភាពច្រើនលើសលប់ដល់ទៅ ១៩២លើក ស្មើនឹង ៦៨% បើប្រៀបធៀបនឹងគោលបំណងនៃការចុះមូលដ្ឋានក្នុងគណបក្សនេះសរុប។ លំដាប់បន្ទាប់គឺការអមដំណើរថ្នាក់ដឹកនាំមាន ៥៨លើក ស្មើនឹង២០%។ ការពង្រឹងបណ្តាញគណបក្សមានចំនួន ៣២លើក (ស្មើនឹង ១១%) និងការចូលរួមវេទិកាសាធារណៈមានតិចតួចគឺ ២លើក (១%) ប៉ុណ្ណោះ។ ខុមប្រែ្វល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះអន្តរាគមន៍ដែលធ្វើឡើងដោយតំណាងរាស្ត្រគណបក្សនេះទេ។

ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជាៈ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រ **ទេស ហ៊ាញ** មណ្ឌលបាត់ដំបងបានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ ពិនិត្យភោគផលស្រូវប្រាំង ស្រូវកណ្តាល ស្ថានភាពអាងទឹកកំពីងពួយព្រមទាំងប្រពន្ធ័ប្រឡាយទឹក និងនាំគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តម **ស ខេង** ចុះពិនិត្យព្យាបាលជម្ងឺអោយប្រជាពលរដ្ឋ និងចែកឱសថនៅឃុំកន្ទឺ២ ស្រុកបាណន់។ អ្នកតំណាងរាស្ត្រ **ស ខេង** នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១០ អមដំណើរសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភាអញ្ជើញចុះពិនិត្យស្ថានភាពដី និងគំនូរប្លង់សាងសង់មន្ទីររំលឹកប្រវត្តិសាស្ត្រតស៊ូរបស់គណបក្សប្រជាជនកម្ពុជានៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**-តំណាងរាស្ត្រគណបក្សសមរង្ស៊ីៈ** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបាន**ផ្តោតខ្លាំងលើការសួរសុខទុក្ខ ៩៥លើក** (ស្មើនឹង៤៦% នៃការចុះមូលដ្ឋានរបស់គណបក្សនេះសរុប) និង**ការពង្រឹងបណ្តាញគណបក្ស ៩២លើក (ស្មើនឹង៤៣%)**។ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបាននាំមុខតំណាងរាស្ត្រគណបក្សដទៃទៀតក្នុងការចូលរួមវេទិកាសាធារណៈដែលមាន ៥លើក (ស្មើនឹង ៥%) ហើយការចុះជួយអន្តរាគមន៍ដែលធ្វើឡើងដោយគណបក្សនេះមាន ៦លើក ស្មើនឹង៦%។

ការចុះមូលដ្ឋានខ្លះៗរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីដូចជា នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ **នុត រំដួល** បានចុះទៅជួយអន្តរាគមន៍ជួយតំណាងប្រជាពលរដ្ឋនៅ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលត្រូវតុលាការខេត្តកោះហៅមកសាកសួររឿងទំនាស់ដីធ្លី ជាមួយក្រុមហ៊ុនរបស់លោកលីយ៉ុងផាត់ ហើយបានឧបត្ថម្ភប្រាក់ចំនួន ១០ម៉ឺនរៀល ដល់ប្រជាពលរដ្ឋសំរាប់ដោះស្រាយការហូបចុក។ អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប **កែ សុវណ្ណរតន៍** នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១០ បានអញ្ជើញចូលរួមវេទិកាស្តីពី "ព្រៃសហគមន៍លិចទឹក" នៅឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាម។

**-តំណាងរាស្ត្រគណបក្សហ៊្វុនស៊ិនប៉ិច:** អ្នកតំណាងរាស្ត្រគណបក្សនេះទាំងពីររូបសុទ្ធតែបានចុះមូលដ្ឋានសរុប១៨លើក ដោយផ្តោតលើការចុះ**ពង្រឹងបណ្តាញបក្ស ៨លើក** (ស្មើនឹង៤៤% នៃការចុះមូលដ្ឋានសរុប) និងសួរសុខទុក្ខប្រជាពលរដ្ឋ ៦លើក (ស្មើនឹង ៣៣%) ដោយឡែកមានតិចតួចសម្រាប់ការចុះអមដំណើរ មាន ៣លើក (១៧%) និងការចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈ ១លើក (៦%)។ ដូចជាកាលពីថ្ងៃទី២១ ខែតុលា ២០១០ តំណាងរាស្ត្រ **ញឹក ប៊ុនឆៃ** ចុះសួរសុខទុក្ខប្រជាពលរដ្ឋនិងត្រួតពិនិត្យច្រកល្បៀងខ្មែរ ថៃ នៅភូមិស្ទឹងបត់ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត និងនៅថ្ងៃដដែលនោះបានអញ្ជើញចូលរួមវេទិការបស់គណៈកម្មាធិការខុមហ្វ្រែលស្តីពី ការបោះឆ្នោត និងលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា នៅសណ្ឋាគារព្រះច័ន្ទ ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**-តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស:** តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើការពង្រឹងបក្ស និងចុះសួរសុខទុក្ខ ចែកអំណោយ ដែលមានចំនួនស្មើគ្នា គឺ៥លើក (ឬ៣៨%) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ ២លើក (ឬ១៦%) ខណៈការអមដំណើរមាន ១លើក (៨%)។ អ្នកតំណាងរាស្ត្រ **កឹម សុខា** ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ អមដំណើរដោយអ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** បានអញ្ជើញចុះទៅភូមិឧត្តម ឃុំព្រែកក្របៅ ស្រុកពាមជរខេត្តព្រៃវែង គោលបំណងសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ដែលមានអ្នកចូលរួមប្រហែល៥០០នាក់ផងដែរ។

**-តំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ៖** ខុមហ្វ្រែល ទទួលបានតែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ **សៅ រ៉ានី** ប៉ុណ្ណោះសម្រាប់គណបក្សនេះ ដែលបានចុះមូលដ្ឋានសរុប ៣លើក ក្នុងគោលបំណងចូលរួមវេទិកា (២ លើក) និងពង្រឹងបណ្តាញគណបក្ស (១ លើក)។ ឧទាហរណ៍ អ្នកតំណាងរាស្ត្រ **សៅ រ៉ានី** មណ្ឌលព្រៃវែងកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០ បានចូលរួមប្រកាសពីការរួបរួមរវាងគណបក្សជាតិនិយម និងគណបក្សហ៊្វុនស៊ិនប៉ិចទៅជាគណបក្សតែមួយ ដែលមានសមាជិកបក្សចូលរួមប្រមាណ៣០០នាក់នៅទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិចក្នុងរាជធានីភ្នំពេញ។

***តារាងទី ២៖ អ្នកតំណាងរាស្ត្រដែលចុះមូលដ្ឋានច្រើនជាងគេ៦រូប***

| ល.រ | ឈ្មោះ តំណាងរាស្ត្រ | គណបក្ស | គោលបំណង | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | អន្តរាគមន៍ | សួរសុខទុក្ខ | ពង្រឹងបក្ស | វេទិកា | អមដំណើរ | |
| ១ | ទេព ង៉ាញ | ប្រជាជនកម្ពុជា | ០ | ១៤ | ០ | ០ | ៤ | **១៨** |
| ២ | យឹម ឆៃលី | ប្រជាជនកម្ពុជា | ០ | ១២ | ០ | ០ | ៥ | **១៧** |
| ៣ | យន្ត ថារូ | សម រង្ស៊ី | ១ | ១២ | ៣ | ១ | ០ | **១៧** |
| ៤ | ជួញ សុឆៃ | ប្រជាជនកម្ពុជា | ០ | ១២ | ០ | ១ | ៤ | **១៧** |
| ៥ | ញឹម វណ្ណដា | ប្រជាជនកម្ពុជា | ០ | ១៥ | ០ | ០ | ១ | **១៦** |
| ៦ | ញឹក ប៊ុនឆៃ | ហ៊្វុនស៊ិនប៉ិច | ០ | ៦ | ៦ | ១ | ៣ | **១៦** |

អ្នកតំណាងរាស្ត្រដែលចុះមូលដ្ឋាននាំមុខគេ៦ រូបភាគច្រើនមកពីគណបក្សប្រជាជនកម្ពុជាដែលមានរហូតដល់៤រូប។ អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមណ្ឌលបាត់ដំបង **ទេញ ហ៊ាញ** បាននាំមុខគេក្នុងការចុះមូលដ្ឋានសរុបបាន ១៨លើក តាមពីក្រោយដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមណ្ឌលបន្ទាយមានជ័យ **យឹម ឆៃលី** អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យមកពីគណបក្សសមរង្ស៊ី **យន្ត ថារូ** និងអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមណ្ឌលបាត់ដំបង **ជួញ សុឆៃ** ដែលម្នាក់ៗបានចុះមូលដ្ឋានស្មើគ្នាៗចំនួន**១៧លើក**។ អ្នកតំណាងរាស្ត្រ **ញឹម វណ្ណដា** មណ្ឌលព្រៃវែងមកពីគណបក្សប្រជាជនកម្ពុជា អ្នកតំណាងរាស្ត្រ **ញឹក ប៊ុនឆៃ** មណ្ឌលបន្ទាយមានជ័យមកពីគណបក្សហ្វ៊ុនស៊ិនប៉ិចបានចុះមូលដ្ឋានម្នាក់ៗ ១៦លើក ដូចគ្នា។

អ្នកតំណាងរាស្ត្រទាំង៦ រូបនេះក៏ផ្តោតការចុះមូលដ្ឋានរបស់ខ្លួនក្នុងការជួបសួរសុខទុក្ខប្រជាពលរដ្ឋ និងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន ចំណែកការចុះមូលដ្ឋានដើម្បីអន្តរាគមន៍ជួយប្រជាពលរដ្ឋកំពុងមានជម្លោះ និងការចូលរួមក្នុងវេទិកា សិក្ខាសាលាគឺ តំណាងរាស្ត្រ **យន្ត ថារូ** នាំមុខគេក្នុងចំណោមតំណាងរាស្ត្រទាំង ៦រូប។

❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄❄